# សម្លឹងមើលកម្ពុជាក្រោមការផ្លាស់ប្តូរជំនាន់នៃអ្នកដឹកនាំប្រទេស




ប្រវត្តិសាស្ត្រថ្មីមួយនៃនយោបាយកម្ពុជាត្រូវបានកត់ត្រាទុក កាលពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០២៣ គ្រាដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានដឹកនាំប្រទេសជិត ៤០ ឆ្នាំ បានប្រកាសលាលែងពីតំណែង ហើយផ្ទេរតំណែងនេះទៅឱ្យកូនប្រុសច្បងរបស់លោក ដែលជាមេបញ្ជាការកងទ័ពជើងគោក បន្ទាប់ពីគណបក្សប្រជាជនកម្ពុជារបស់លោក បានឈ្នះអាសនៈភាគច្រើននៅរដ្ឋសភាជាតិពីការបោះឆ្នោតជាតិអាណត្តិទី ៧។ សម្រាប់ពលរដ្ឋទូទៅ នេះជាការផ្លាស់ប្តូរជំនាន់នៃអ្នកដឹកនាំប្រទេសដ៏កម្រនិងដែលត្រូវបានរៀបចំទុកជាមុន

ឱ្យសមស្របទៅនឹងបរិបទនិងបច្ចុប្បន្នភាពនៃប្រជាសាស្ត្រ និងសេដ្ឋកិច្ចកម្ពុជា។ សម្រាប់ក្រុមអ្នកជំនាញ ការផ្លាស់ប្តូរមុខមាត់មេដឹកនាំនេះ គឺជាកិច្ចការដ៏ចាំបាច់ ខណៈស្ថានភាពសេដ្ឋកិច្ចសង្គម សិទ្ធិសេរីភាព និងនយោបាយក្នុងប្រទេសកំពុងបន្តប្រឈមនឹងបញ្ហាចាស់ឫសមួយចំនួនជាបន្តបន្ទាប់ ស្របពេលដែលការផ្លាស់ប្តូរមេដឹកនាំនេះកើតចេញពីគណបក្សនយោបាយតែមួយដែលខ្វះខ្លឹមសារប្រជាធិបតេយ្យ។ អ្នកនាង កាន់ វិច្ឆិកា អ្នកស្រី ធីតា វីន និងអ្នកនាង ទែន សុខស្រីនិត រាយការណ៍អំពីរឿងនេះ៕